

ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

លេខទី ១២ ត្រីមាសទី២ ឆ្នាំ ២០១៩ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension



# បទពិសោធន៍ជោគជ័យលើ ការងារចិញ្ចឹមគោកែប្រែពូជ

## របស់កសិករ អ៊ុក ម៉ាប់ រស់នៅភូមិអង្គរគគី ឃុំតាភេន ស្រុកត្រាំកក់ ខេត្តតាកែវ

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យលើការងារ និងមុខរបរផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារប្រកបរបរកសិកម្មមកចងក្រង និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាកសិករ សហគមន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀតដើម្បីជាចំណេះដឹងបន្ថែម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម បានលើកយកបទពិសោធន៍ជោគជ័យ របស់កសិករឈ្មោះ អ៊ុក ម៉ាប់ រស់នៅភូមិអង្គរគគី ឃុំតាភេន ស្រុកត្រាំកក់ ខេត្តតាកែវ ជាកសិករឆ្នើម ធ្លាប់ទទួលបានជ័យលាភី ក្នុងឱកាសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទធ្វើការជ្រើសរើសរកកសិករឆ្នើមប្រចាំឆ្នាំ លើការងារចិញ្ចឹមសត្វមកបង្ហាញជូនដូចខាងក្រោម៖

### ១- អំពីប្រវត្តិ

កសិករឈ្មោះ អ៊ុក ម៉ាប់ មានទីលំនៅបច្ចុប្បន្នក្នុងភូមិអង្គរគគី ឃុំតាភេន ស្រុកត្រាំកក់ ខេត្តតាកែវ និងគ្រួសារបានរៀបរាប់ប្រាប់ថា ការងារចិញ្ចឹមគោដំបូងរបស់គាត់ គឺគាត់ចិញ្ចឹមតែពូជគោក្នុងស្រុក ហើយចិញ្ចឹមតាមលក្ខណៈធម្មជាតិលែងពាសវាល ពាសកាល មិនមានបច្ចេកទេសក្នុងការថែទាំដូចជាការផ្តល់ចំណី ការចាក់វ៉ាក់សាំងការពារជំងឺ ពិសេសមិនមានផែនការចិញ្ចឹមសត្វសម្រាប់បំពេញឱ្យតម្រូវការទីផ្សារឡើយដែលជាហេតុ ធ្វើឱ្យគាត់ទទួលបានតម្លៃថោក។ បន្ទាប់ពីទទួលបាននូវការបណ្តុះបណ្តាលពីបច្ចេកទេសចិញ្ចឹមគោ



ការចិញ្ចឹមគោរបស់កសិករ អ៊ុក ម៉ាប់ មុនទទួលបានការបណ្តុះបណ្តាល



សកម្មភាពនៃការចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមគោតាមបែបសិប្បនិម្មិតរបស់កសិករ អ៊ុក ម៉ាប់

ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ និងតាមរយៈភ្នាក់ងារផ្សព្វផ្សាយ ពេទ្យសត្វភូមិ ចាប់តាំងពីឆ្នាំ២០១៦

មក កសិករ អ៊ុក ម៉ាប់ បានផ្លាស់ប្តូរទម្លាប់ពីការចិញ្ចឹមគោតាមបែបធម្មជាតិ មកធ្វើការចិញ្ចឹមតាមលក្ខណៈកែប្រែពូជវិញ ហើយមកដល់ពេលបច្ចុប្បន្ន ធ្វើឱ្យគាត់មានជីវភាពធូរធារ ដោយបានសាងសង់គេហដ្ឋានល្អ កូនរបស់ត្រូវបានបញ្ជូនទៅសាលារៀនគ្រប់គ្នា មានសម្ភារប្រើប្រាស់ដូចជា ម៉ូតូល្អ ម៉ាស៊ីនបូមទឹក រឺម៉កដឹក គ្រឿងសង្ហារឹម និងសម្ភារផ្សេងៗមួយចំនួនទៀត។



គេហដ្ឋានកសិករ អ៊ុក ម៉ាប់ ក្រោយទទួលបានភាពជោគជ័យលើការងារចិញ្ចឹមគោ



សម្ភារក្នុងគេហដ្ឋានកសិករ អ៊ុក ម៉ាប់ ក្រោយទទួលបានភាពជោគជ័យលើការងារចិញ្ចឹមគោ

## ២- អំពីដំណើរការចិញ្ចឹម

កសិករ អ៊ុក ម៉ាប់ បានរៀបរាប់ប្រាប់ថា ការចិញ្ចឹមគោតាមរបៀបកែប្រែពូជនេះ គឺគាត់បានយកមេគោពូជក្នុងស្រុកទៅបង្កាត់ជាមួយពូជគោនាំចូល ក្នុងនោះមានពូជប្រាម៉ាន់ សាន់តា ស៊ីមប្រា និងស៊ីមម៉ុងតាល់ ដោយបានចាប់ផ្តើមចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់ពេលបច្ចុប្បន្ននេះចិញ្ចឹមបានមេ៥ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៩នេះ គាត់ទទួលបានពូជគោបង្កាត់នេះចំនួន ៨ ក្បាល ហើយបញ្ចេញលក់បានចំនួន ៤ ក្បាល ទទួលបានទឹកប្រាក់ចំនួន១៤,០០០,០០០



ពូជគោ ប្រាម៉ាន់ ដែលគេយកស្ពែមមកបង្កាត់ពូជគោក្នុងស្រុក

រៀល។ កសិករ អ៊ុក ម៉ាប់ បានរៀបរាប់បន្តទៀតថា ការដែលគាត់ទទួលបានភាពជោគជ័យ លើការងារចិញ្ចឹមគោ តាមរបៀបកែប្រែពូជនេះក៏ដោយសារតែគាត់ទទួលបានការបណ្តុះបណ្តាល ពីការិយាល័យផលិតកម្ម និងបសុព្យាបាលនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ បានចុះមកធ្វើការផ្សព្វផ្សាយនៅមូលដ្ឋានរបស់គាត់ផ្ទាល់ ហើយធ្វើឱ្យគាត់មានការចាប់អារម្មណ៍ទៅលើមុខរបរមួយនេះ។



សកម្មភាពនៃការចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមគោតាមបែបសិប្បនិម្មិតរបស់កសិករ អ៊ុក ម៉ាប់

ក្នុងពេលបច្ចុប្បន្ន មុខរបរចិញ្ចឹមគោតាមបែបសិប្បនិម្មិតបានរីកសាយភាយ ទៅដល់កសិករដទៃទៀត ជាច្រើនគ្រួសារ ជាក់ស្តែងតាមរបាយការណ៍ បូកសរុបប្រចាំឆ្នាំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ ក្នុងឆ្នាំ ២០១៨ កន្លងមកនេះ បានបង្ហាញឱ្យឃើញថា មេគោពូជក្នុងស្រុកដែលបានធ្វើការបង្កាត់មានចំនួន១២០០ក្បាល និងទទួលបានកូនគោ ជាពូជគោសិប្បនិម្មិតចំនួន៨០០ក្បាល។ កសិករឈ្មោះ អ៊ុក ម៉ាប់ បានឱ្យដឹងទៀតថា មូលហេតុដែលធ្វើឱ្យប្រជាកសិករនៅតំបន់នេះ បានងាកមកចាប់យករបរ



កូនគោដែលបានឆ្លងកាត់ការបង្កាត់រវាងពូជប្រាម៉ាន់ និងមេពូជក្នុងស្រុករបស់កសិករ អ៊ុក ម៉ាប់

ចិញ្ចឹមគោតាមរបៀបកែប្រែពូជនេះច្រើនដោយសារ ពូជគោប្រភេទប្រាម៉ាន់ សាន់តា ស៊ីមប្រា និងស៊ីមម៉ុងតាល់ ដែលជាពូជនាំចូលនេះ មានតម្លៃថ្លៃជាង ពូជគោក្នុងស្រុកយើងច្រើន ដែលក្នុងមួយក្បាលៗ អាចពី ១០០០-២៥០០ដុល្លារសហរដ្ឋអាមេរិក ហើយចំណាយពេលវេលានៃការចិញ្ចឹមខ្លី។

កសិករ អ៊ុត ម៉ាប់ បានបន្តទៀតថា ការចិញ្ចឹមតាមបែបសិប្បនិម្មិត សំខាន់យើងត្រូវមានមេគោ ជាពូជក្នុងស្រុក សម្រាប់ធ្វើការបង្កាត់ជាមួយពូជនាំចូល ដើម្បីកូនគោ



មេគោពូជរបស់កសិករ អ៊ុក ម៉ាប់ សម្រាប់ធ្វើបង្កាត់



ការបង្កាត់តាមបែបសិប្បនិម្មិត



ស្មៅចំណីសត្វដែលកសិករ អ៊ុក ម៉ាប់ បានដាំនៅចម្ការរបស់គាត់សម្រាប់ជាចំណី



ការផ្ដល់ចំណីបំប៉នដល់គោមេក្រោយធ្វើការបង្កាត់

ពូជល្អសម្រាប់លក់បន្ត ក្រៅពីនេះទុកធ្វើមេពូជបន្តទៀត។ តាមបទពិសោធន៍ជាក់ស្តែងរបស់គាត់ ការចិញ្ចឹមដែលធ្វើឱ្យទទួលបានលទ្ធផលល្អ ចាំបាច់ត្រូវមានការយកចិត្តទុកដាក់លើកត្តាសំខាន់ៗមួយចំនួនដូចជា ការជ្រើសរើសពូជយកមកបង្កាត់ ការរៀបចំទ្រុង ការដាំស្មៅសម្រាប់ផ្តល់ចំណី និងការថែទាំ ចំពោះប្រភេទស្មៅដែលគាត់បានផ្តល់ជាចំណីសម្រាប់គោរបស់គាត់មានដូចជា ប្រភេទបារាំង ស្មៅកំផ្លូង ដែលពូជស្មៅទាំងនេះគាត់ទទួលបានពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកផ្តល់ឱ្យ លោកបានរៀបរាប់ប្រាប់បន្ថែមទៀតថា ស្មៅចំណីនេះមានសារសំខាន់ណាស់ ព្រោះថាបើយើងដាំស្មៅបាន ធ្វើឱ្យយើងចំណេញថវិកា និងពេលវេលា ហើយពូជគោបង្កាត់នេះវាចូលចិត្តស៊ីស្មៅប្រភេទនេះណាស់ ស្មៅប្រភេទនេះសម្បូរទៅដោយសារធាតុចិញ្ចឹមធ្វើឱ្យគោឆាប់ធំ។

ចំពោះការថែទាំកសិករ អ៊ុក ម៉ាប់ បានរៀបរាប់ឱ្យដឹងថា គាត់បានធ្វើការសម្អាតទ្រុងជាប្រចាំ ចាក់វ៉ាក់សាំងការពារជំងឺសត្វ មានការផ្តល់ទឹក ចំណីឱ្យគោស៊ីបានគ្រប់គ្រាន់។



ការធ្វើអនាម័យទ្រុង



ការលាងសម្អាតមុនពេលបញ្ចូលគោក្នុងក្រោល

## ៣- ការវិភាគសេដ្ឋកិច្ច

ក្រោយមានការផ្លាស់ប្តូរ ពីការចិញ្ចឹមតាមបែបធម្មជាតិមកចិញ្ចឹមតាមលក្ខណៈកែប្រែពូជ កសិករ អ៊ុក ម៉ាប់ បានរៀបរាប់ប្រាប់បន្ថែមទៀតថា ក្នុងពេលបច្ចុប្បន្នគាត់មានលទ្ធភាព



គោយន្តសម្រាប់ប្រើប្រាស់ឱ្យការងារចិញ្ចឹមគោ
របស់កសិករ អ៊ុក ម៉ាប់

សាងសង់ផ្ទះបានពីរខ្នង ទិញម៉ូតូល្មមជិះ មានសម្ភារសម្រាប់ប្រើប្រាស់បម្រើឱ្យការងារចិញ្ចឹមគោ ដូចជារឺម៉កដឹកស្មៅ ម៉ាស៊ីនប៉ូមទឹកសម្រាប់លាងសម្អាតគោ មាន គ្រឿងសង្ហារឹមដាក់តាំងក្នុងផ្ទះ មានលទ្ធភាពទិញដីសម្រាប់ពង្រីកការដាំស្មៅចំណីសត្វ និងមានលទ្ធភាពបញ្ជូនកូនទៅសាលារៀនបានគ្រប់ៗគ្នា ពិសេសធ្វើឱ្យគ្រួសារគាត់បានរស់នៅជួបជុំគ្នាមិនចាំបាច់ធ្វើចំណាកស្រុក។



ម៉ាស៊ីនបូមទឹករបស់កសិករ អ៊ុក ម៉ាប់ សម្រាប់
បម្រើឱ្យការងារចិញ្ចឹមគោរបស់គាត់



ក្រុមគ្រួសារកសិករ អ៊ុក ម៉ាប់ រស់នៅជួបជុំគ្នាក្រោយ
ទទួលបានភាពជោគជ័យលើការងារចិញ្ចឹមគោ

ជាចុងក្រោយកសិករ អ៊ុក ម៉ាប់ បានប្រាប់ឱ្យដឹងពីផែនការចិញ្ចឹមគោបន្តរបស់គាត់ថា នឹងពង្រីកបន្ថែមលើមុខរបរនេះ និងមានគម្រោងធ្វើការផ្សព្វផ្សាយទៅដល់កសិករដទៃទៀត ឱ្យចូលរួមចិញ្ចឹមគោដូចគាត់ដែរ៕

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ
- កសិករឈ្មោះ អ៊ុក ម៉ាប់ មានទីលំនៅក្នុងភូមិអង្គរគតី ឃុំតាភេន ស្រុកត្រាំកក់ ខេត្តតាកែវ

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០១១ ៦៣៣ ៨២៩